00362849

D188/3

# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 11 / 08 / 2009
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: សម្ងាត់ CONFIDENTIEL CONFIDENTIEL 13/08/2009

~~ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ជាសម្ងាត់:~~

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

សាធារណៈ PUBLIC 26/01/2010

---

## សេចក្តីឆ្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំអោយមានកិច្ចស៊ើបសួរ ស្តីអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ

---

<u>ដាក់ដោយ</u>៖

សហមេធាវីរបស់លោក អៀង សារី

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

សហចៅក្រមស៊ើបអង្កេត

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមទៅតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងរបស់ អវតក ("វិធាន") តាមរយៈនេះសូមដាក់សេចក្តីឆ្លើយតបទៅនឹង សំណើលើកទីពីររបស់សហមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី សុំអោយមានកិច្ចស៊ើបសួរស្តីអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ដែលបានដាក់ធ្វើកាលពីថ្ងៃទី ១៥ កក្កដា ២០០៩ ("សំណើ")[1]។ សំណើនេះអះអាងថា "ការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") ទើបបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម ដើម្បីធ្វើការស៊ើបអង្កេតលើបណ្តឹងជាក់លាក់ចំនួនប្រាំចំពោះអង្គហេតុទាក់ទិននឹងការរៀបអាពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ"[2] ប៉ុន្តែ "មិនមានកិច្ចស៊ើបសួរណាមួយត្រូវបានធ្វើឡើងដោយ កសចស នៅឡើយទេ ឬក៏មិនទំនងជាមានកិច្ចស៊ើបសួរណាមួយនឹងត្រូវធ្វើឡើងនៅពេលអនាគតដែរ"[3]។ ហេតុដូច្នេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ("ដើមបណ្តឹងរដ្ឋប្បវេណី") ស្នើសុំ "អោយមានកិច្ចស៊ើបសួរទាក់ទិននឹងការកើតមានឡើងនៃអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងរយៈពេលពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងកំណត់ចំណាត់ប្រភេទផ្នែកច្បាប់នៃអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ"[4] ។ នៅក្នុងសំណើនោះ ដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមដោយគ្មានការអនុញ្ញាត ដើម្បីធ្វើអោយមានការពាក់ព័ន្ធគ្នារវាងអាពាហ៍ពិពាហ៍ដោយបង្ខំជាមួយនឹងឧក្រិដ្ឋកម្មផ្សេងទៀត ហើយចាត់ថ្នាក់វាចូលទៅក្នុងយុត្តាធិការ[5]របស់ អវតក តាមរយៈកិច្ចព្រមព្រៀង[6]បង្កើត អវតក ឬ ដូចជាទម្រង់មួយនៃ "អំពើអមនុស្សធម៌ផ្សេងៗ[7]" ដែលស្ថិតក្រោមច្បាប់បង្កើតតុលាការនេះ[8]។ តែឯកឯងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មមួយប្រឆាំងមនុស្សជាតិមិនចូលទៅក្នុងយុត្តាធិការរបស់ អវតក ឡើយ។ សំណើនេះ ក៏ខកខានមិនបានបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំគឺជាឧក្រិដ្ឋកម្ម

---

[1] សំណើនេះត្រូវបានជូនដំណឹងពីការដាក់ឯកសារកាលពីថ្ងៃទី ២៣ កក្កដា ២០០៩ ។

[2] *ដូចយោងខាងលើ* កថាខណ្ឌ ១ ។

[3] *ដូចយោងខាងលើ* ។

[4] *ដូចយោងខាងលើ* ។

[5] *ដូចយោងខាងលើ* កថាខណ្ឌ ១០ ។

[6] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង")។

[7] សំណើ កថាខណ្ឌ ១៩ ដល់ ២២ ។

[8] ច្បាប់ស្តីពីការបង្កើតអោយមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើវិសោធនកម្ម ហើយប្រកាសអោយប្រើកាលពីថ្ងៃទី ២៧ តុលា ២០០៤ ("ច្បាប់បង្កើត អវតក")។

00362851



មួយឋិតក្រោមច្បាប់អន្តរជាតិនៅក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩ ។ ដោយមិនមានការបង្ហាញភស្តុតាងនេះ កសចស ត្រូវហាមឃាត់មិនអោយធ្វើការស៊ើបសួរទៅលើឧក្រិដ្ឋកម្មនេះ។

## I. សេចក្តីផ្តើម

១. មេធាវីការពារក្តីនឹងបង្ហាញថា៖

ក. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកមួយ មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក ឡើយ តាមច្បាប់បង្កើតតុលាការនេះ ឬកិច្ចព្រមព្រៀង ទាំងជាឧក្រិដ្ឋកម្មដាច់ដោយឡែកតែឯង ជាអំពើអមនុស្សធម៌ ឬជាអំពើរំលោភសេពសន្ថវៈ ជាការដាក់មនុស្សជាទាសករផ្លូវភេទ ឬការមានគភ៌ដោយបង្ខំ ។

ខ. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឋិតក្រោមច្បាប់ កម្ពុជា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩ ។

គ. មិនមានកាតព្វកិច្ចសម្រាប់ កសចស ដែលត្រូវតែផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ឃ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលឋិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនអាចអនុវត្ត ដោយផ្ទាល់នៅក្នុងតុលាការជាតិរបស់កម្ពុជាទេ

ង. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលឋិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានផ្ទុកនូវធាតុ ផ្សំអត្តនោម័តនៃការរើសអើង ឬក៏ អវតក អាចដាក់កម្រិតដោយស្របច្បាប់លើយុត្តាធិការ របស់ខ្លួនក្នុងការបញ្ចូលនូវធាតុផ្សំនេះ។

## II. អង្គច្បាប់

២. មេធាវីការពារក្តីរួមបញ្ចូលគ្នា តាមរយៈសេចក្តីយោងទៅកាន់សេចក្តីសន្និដ្ឋាននានារបស់ខ្លួនពីមុនៗ ស្តីពីអង្គច្បាប់ទាក់ទងនឹង៖ (១) ការស៊ើបអង្កេតបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម[9] (២) សំណើសុំអោយបំពេញកិច្ចស៊ើបសួរ[10]

[9] *សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើសុំ អោយបំពេញកិច្ចស៊ើបសួររបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ និងសំណើ សុំបន្ថែមចំនួនទំព័រដែលបានកំណត់ ចុះថ្ងៃទី ៥ សីហា២០០៩ កថាខណ្ឌ ២-៤ ("ចម្លើយតបការបាត់ខ្លួនដោយបង្ខំ")។

[10] *ដូចយោងខាងលើ* កថាខណ្ឌ ៥ ។

និង (៣) ច្បាប់សារធាតុដែលអនុវត្តនៅ អវតក[11]។

### III. ភាពអាចទទួលយកបាននៃសំណើសុំអោយបំពេញកិច្ចស៊ើបសួរ

៣. មិនមានការថ្លែងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬទំនាក់ទំនងផ្លូវភេទដោយបង្ខំ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ("ដីកាសុំអោយស៊ើបសួរ") ដែលដាក់ធ្វើដោយការិយាល័យសហព្រះរាជអាជ្ញា កាលពីថ្ងៃ ១៨ កក្កដា ២០០៧ ប្រឆាំងនឹង នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធិ និង ឌុច[12] ឡើយ។ កាលពីថ្ងៃទី ៣០ មេសា ២០០៨ ការិយាល័យសហព្រះរាជអាជ្ញា ("កសព")[13] បានដាក់ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមជាកិច្ចឆ្លើយតបទៅនឹងដីកាបញ្ជូនរឿងអោយពិនិត្យ[14]របស់ កសចស ទាក់ទងនឹងបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី "ដែលផ្ទុកនូវការចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ទំនាក់ទំនងផ្លូវភេទដោយគ្មានការយល់ព្រម និងការគំរាមសម្លាប់បើសិនជាបុគ្គលណាបដិសេធមិនប្រព្រឹត្តទំនាក់ទំនងផ្លូវភេទដោយបង្ខំ"[15] ។ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម ដាក់កម្រិតនូវការស៊ើបសួរបន្ថែមនេះត្រឹមតែ "បណ្តឹងជាក់លាក់" ទាំងនេះតែប៉ុណ្ណោះ[16]។

៤. ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ អនុញ្ញាតបន្ថែមដល់ កសចស អោយស៊ើបសួរ "អង្គហេតុនានាផ្សេងទៀតដែល ដោយហេតុថាអង្គហេតុទាំងនោះជួយដល់ការកំណត់ទាំង (ក) ធាតុផ្សំយុត្តាធិការដែលចាំបាច់ដើម្បីបង្កើតថា តើអង្គហេតុនានាដែលមានយោងនៅក្នុងកថាខណ្ឌ ២ បង្កើតបានជាឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក ដែរឬទេ ឬ (ខ) ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា អៀង សារី ខៀវ សំផន ឬ អៀង ធីរិទ្ធ ដែលទាក់ទងនឹង

---

[11] *ដូចយោងខាងលើ* កថាខណ្ឌ ៦-៨ ។

[12] *សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ចុះថ្ងៃទី ១៨ កក្កដា ២០០៧ ។ ឌុច ត្រូវបានបំបែកចេញតាមរយៈដីកាសម្រេចចុះថ្ងៃទី ១៩ កញ្ញា ២០០៧ ។ *សូមមើល សូមមើល* ការវិវឌ្ឍន៍នៃរឿងក្តីរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១ វិច្ឆិកា ២០០៧ នៅពេលដែលសាធារណៈជនត្រូវបានជូនដំណឹងថា "កាលពីថ្ងៃទី ១៩ កញ្ញា ២០០៧ [កសចស] បានសម្រេចចេញដីកាបំបែកសំណុំរឿងរបស់ ឌុច ដើម្បីធានាការគ្រប់គ្រងយុត្តិធម៌ល្អ"។

[13] *សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់ សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម ចុះថ្ងៃទី ៣០ មេសា ២០០៨ ("ចម្លើយតបរបស់ កសព") ។

[14] *សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី ១៣ មីនា ២០០៨។

[15] ចម្លើយតបរបស់ កសព កថាខណ្ឌ ១ ។

[16] *ដូចយោងខាងលើ* កថាខណ្ឌ ២ ។

00362853



អង្គហេតុបែបនោះ"[17] ។

៥. សំណើ/ការអនុញ្ញាតរបស់ កសព ដល់ កសចស ដើម្បីស៊ើបសួរ "អង្គហេតុដទៃផ្សេងទៀត" គឺមានលក្ខណៈស្រពេចស្រពិលដែលមិនអាចអនុញ្ញាតអោយបាន។ កសព កំណត់ព្រំដែននៃកិច្ចស៊ើបសួររបស់ កសចស តាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម ។ កសចស ត្រូវចងភ្ជាប់ដោយការកម្រិតទាំងនេះ[18]។ កសព មិនអាចផ្ទេរនូវការទទួលខុសត្រូវរបស់ខ្លួនទៅ កសចស ដោយអនុញ្ញាតអោយ កសចស ធ្វើការស៊ើបសួរ "អង្គហេតុផ្សេងទៀត" ដែលខ្លួនយល់ឃើញថាសក្តិសមនោះទេ។ ហេតុដូច្នេះ វិសាលភាពដែលឥតដែនកំណត់នៃកិច្ចស៊ើបសួរដែលស្នើឡើងដោយ កសព នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម ដាច់ខាតមិនត្រូវបានគេពិចារណាឡើយ។ ប៉ុន្តែ នៅក្នុងកម្រិតមួយដែលសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវកម្រិតត្រឹមតែការបំពេញកិច្ចស៊ើបសួររបស់ កសចស ទៅលើអង្គហេតុជាក់លាក់ដែលលើកឡើងនៅក្នុងបណ្តឹងទាំងប្រាំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ ករណីនេះគឺវាស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរយ៉ាងត្រឹមត្រូវ។

៦. នៅក្នុងសំណើនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានផ្តល់នូវការគាំទ្រសម្រាប់ការអះអាងរបស់ខ្លួនថា "មិនមានកិច្ចស៊ើបសួរណាមួយត្រូវបានធ្វើឡើងដោយ កសចស នៅឡើយទេ ឬក៏មិនទំនងជាមានកិច្ចស៊ើបសួរណាមួយនឹងត្រូវធ្វើឡើងនៅពេលអនាគតដែរ"[19] ។ គួរអោយស្តាយ កង្វះព័ត៌មានដែលផ្តល់ដោយ កសចស ស្តីពីយុទ្ធសាស្ត្រ នីតិវិធី និងវិសាលភាពនៃកិច្ចស៊ើបសួរគឺជារឿងមួយគួរអោយបារម្ភ បណ្តោយអោយគូភាគីកើតក្តីសង្ស័យថា តើអង្គហេតុជាក់លាក់មួយចំនួននឹងត្រូវបាន កសចស ធ្វើការស៊ើបសួរដែរឬទេ ហើយបើសិនជាមានធ្វើមែនតើគេធ្វើឡើងនៅពេលណា[20] ។ ហេតុដូច្នេះ មេធាវីការពារក្តីគឺពិតជាគាំទ្រដល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការស្នើសុំព័ត៌មានស្តីពីស្ថានភាពនៃកិច្ចស៊ើបសួររបស់ កសចស ទាក់ទងទៅនឹងអង្គហេតុជាក់លាក់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម។ ជាធម្មតា កសចស <u>ត្រូវតែ</u>ជូនដំណឹងដល់គ្រប់ភាគីទាំងអស់អំពីស្ថានភាពនៃទិដ្ឋភាពជាក់លាក់នេះ

[17] *ដូចយោងខាងលើ* កថាខណ្ឌ ៦ ។

[18] វិធាន ៥៥(២) ។

[19] សំណើ កថាខណ្ឌ ១ ។

[20] *សូមមើលជាទូទៅ* ។*សូមមើលផងដែរ សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើរបស់លោក អៀង សារី សុំអោយបំពេញកិច្ចស៊ើបសួរលើកទីបី ចុះថ្ងៃទី ២១ ឧសភា ២០០៩ ។

នៅក្នុងកិច្ចស៊ើបសួរ ទៅតាមវិធីដែលមានតម្លាភាព និងឆាប់រហ័ស។

## IV. ឧត្ថិករណ៍

### ក. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក ឡើយ

#### ១. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនត្រូវបានបញ្ចូលនៅក្នុងច្បាប់បង្កើត អវតក ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក

៧. ច្បាប់បង្កើត អវតក មិនបានបង្កើតអោយមានទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ឬឧក្រិដ្ឋកម្មនានាឡើយ។ ច្បាប់នេះត្រឹមតែកំណត់យុត្តាធិការលើបទល្មើស (subject-matter) យុត្តាធិការលើពេលវេលា និងយុត្តាធិការលើបុគ្គលរបស់ អវតក ប៉ុណ្ណោះ។ មាត្រា ៥ នៃច្បាប់បង្កើត អវតក មិនបាន "វាយឈ្មោះអាពាហ៍ពិពាហ៍ដោយបង្ខំថាជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនោះទេ"[21]។ មាត្រានេះវាយឈ្មោះអំពើជាក់លាក់មួយចំនួន ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បើសិនជាវាត្រូវបានគេ "ប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើជនស៊ីវិល" ដោយមូលហេតុរើសអើងមួយចំនួន ។ អាពាហ៍ពិពាហ៍ដោយបង្ខំ មិនត្រូវបានរាប់ចូលក្នុងបញ្ជីនៃអំពើទាំងនេះទេ។ ហេតុដូច្នេះ ដោយមានចេតនាដកចេញជាក់ស្តែងនូវអាពាហ៍ពិពាហ៍ដោយបង្ខំពីយុត្តាធិការរបស់ខ្លួន ក្រោមមាត្រា ៥ កសចស ត្រូវបានរារាំងមិនអោយធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសជនត្រូវចោទនានាចំពោះបទល្មើសដែលចោទប្រកាន់នេះ ។

#### ២. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនត្រូវបានបញ្ចូលជាក់លាក់នៅក្នុងកិច្ចព្រមព្រៀងថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក

៨. ទាំងច្បាប់បង្កើត អវតក ទាំងកិច្ចព្រមព្រៀងចែងថា ច្បាប់បង្កើត អវតក គឺជាលិខិតូបករណ៍តែមួយគត់ ដែលអាចកំណត់ដោយស្របច្បាប់នូវយុត្តាធិការរបស់ អវតក[22] ។ បើសិនជា កសចស ពិចារណាថា កិច្ចព្រមព្រៀងក៏អាចកំណត់ផងដែរនូវយុត្តាធិការរបស់ អវតក ហេតុដូច្នេះវាមានទំនាស់រវាងច្បាប់បង្កើត អវតក និងកិច្ចព្រមព្រៀង អញ្ចឹងច្បាប់បង្កើត អវតក ត្រូវតែមានអានុភាព

---

[21] ច្បាប់បង្កើតតុលាការ មាត្រា ៥ ។

[22] *សូមមើល* ចម្លើយតបការបាត់ខ្លួនដោយបង្ខំ កថាខណ្ឌ ១៦-១៨ ។

ជាង[23]។

៩. សូម្បីតែសន្មតថា កសចស អាចសំអាងទាំងស្រុងទៅលើកិច្ចព្រមព្រៀងដើម្បីកំណត់យុត្តាធិការ ជាជាងប្រើប្រាស់ច្បាប់បង្កើត អវតក ក៏កិច្ចព្រមព្រៀង មិនអនុញ្ញាតអោយអាពាហ៍ពិពាហ៍ដោយបង្ខំ យកមកអនុវត្តនៅ អវតក ឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនសំអាងទៅលើអំពើជាក់លាក់ដែលមានរាយឈ្មោះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងមាត្រា ៧ នៃ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")[24] ហើយដែលទទួលយកដោយកិច្ចព្រមព្រៀង[25] ដើម្បីយកមកគាំទ្រនូវចំពោះ ការអះអាងរបស់ខ្លួនថា អាពាហ៍ពិពាហ៍ដោយបង្ខំ គឺស្ថិតនៅក្នុងយុត្តាធិការនៃបទល្មើសរបស់ អវតក ។ នេះគឺជាការផ្ទុយគ្នាដ៏គួរអោយកត់សម្គាល់រវាងសំណើនេះនឹងសំណើលើកទីមួយសុំអោយបំពេញកិច្ចស៊ើបសួររបស់ពួកគេ ទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ[26] ។ ភាពខុសគ្នានេះគឺមានលក្ខណៈច្បាស់លាស់ថា៖ និយមន័យរបស់តុលាការ ICC ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានដកចេញយ៉ាងច្បាស់លាស់នូវអាពាហ៍ពិពាហ៍ដោយបង្ខំចេញពីយុត្តាធិការរបស់ខ្លួន[27] ។ ហេតុដូច្នេះ ដោយសន្មតថា កិច្ចព្រមព្រៀងអាចទទួលយកដោយស្របច្បាប់នូវនិយមន័យបន្ថែមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់លក្ខន្តិកៈតុលាការ ICC[28] ដើម្បីកំណត់យុត្តាធិការរបស់ អវតក ទៅលើឧក្រិដ្ឋកម្មដែលចោទថាបានប្រព្រឹត្តឡើងនៅអំឡុងឆ្នាំ ១៩៧៥-៧៩ វាក៏នៅតែមិនអនុញ្ញាតអោយយក យុត្តាធិការលើបទល្មើសរបស់ អវតក មកផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលគេចោទប្រកាន់នេះឡើយ។

**៣. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនបង្កើតបានជាអំពើអមនុស្សធម៌ផ្សេងៗនៅក្រោមច្បាប់បង្កើត អវតក**

១០. ដើមបណ្តឹងរដ្ឋប្បវេណី អះអាងក្នុងជម្រើសផ្សេងពីនេះវិញថា អវតក មានយុត្តាធិការនៃបទល្មើស

---

[23] *ដូចយោងខាងលើ* កថាខណ្ឌ ១៩-២០ ។

[24] សំណើ កថាខណ្ឌ ៥-៨ ។ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ A/CONF.183/9 ១៧ កក្កដា ១៩៩៨ ។

[25] កិច្ចព្រមព្រៀង មាត្រា ៩ ។

[26] *សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើលើកទីមួយរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំអោយមានកិច្ចស៊ើបសួរស្តីអំពីការបាត់ខ្លួនដោយបង្ខំ ចុះថ្ងៃទី ៣០ មិថុនា ២០០៩ កថាខណ្ឌ ៥ ។

[27] សំណើ កថាខណ្ឌ ១១ ។

[28] លក្ខន្តិកៈនេះត្រូវបានព្រាងនៅក្នុងឆ្នាំ ១៩៩៨ ហើយក្រោយមកបានចូលជាធរមាននៅពេលបួនឆ្នាំក្រោយនៅថ្ងៃទី ១ កក្កដា ២០០២។

ទៅលើការបាត់ខ្លួនមនុស្សដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗ" ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់បង្កើត អវតក[29] ។ ពាក្យដែលថា "អំពើអមនុស្សធម៌ផ្សេងៗ" ទំនងជាមិនត្រឹមត្រូវក្នុងន័យអោយស្របទៅនឹងគោលការណ៍នៃភាពជាក់លាក់ (specificity) ដែលចែងថា "វិធានព្រហ្មទណ្ឌដាច់ខាតត្រូវមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន"[30]។ នៅក្នុងរឿងក្តី *Kupreskić* ខណៈដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការដាក់អោយធ្វើជាពេស្យាចារដោយបង្ខំ ស្ថិតនៅក្រោមប្រភេទខាងលើនេះ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក៏វាមិនបានរួមបញ្ចូលនូវអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ[31]។ ម្យ៉ាងវិញទៀត នៅក្នុងការយល់ឃើញទាក់ទងនឹង ការដាក់អោយធ្វើជាពេស្យាចារដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងមិនបានថ្លែងលំអិតនូវមូលដ្ឋានផ្លូវច្បាប់ជាក់លាក់ចំពោះការអះអាងនេះ ដោយបានត្រឹមតែយោងទៅលើ "លិខិតូបករណ៍អន្តរជាតិសំខាន់ៗ" ប៉ុណ្ណោះ[32]។

១១. ដើមបណ្តឹងរដ្ឋប្បវេណីសំអាងទៅលើយុត្តិសាស្ត្រមកពីតុលាការពិសេសសៀរ៉ាលេអូន ("តុលាការ SCSL") យកមកគាំទ្រនូវការអះអាងរបស់ខ្លួនថា អាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាអំពើអមនុស្សធម៌[33]។ ចំណុចនេះមិនគាំទ្រដល់ការសន្និដ្ឋានថា អាពាហ៍ពិពាហ៍ដោយបង្ខំ បង្កើតបានជាអំពើអមនុស្សធម៌ឡើយ។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Sasay* បានត្រឹមតែកត់សម្គាល់ថា អយ្យការ "ចោទប្រកាន់ជនជាប់ចោទពីបទ "អំពើអមនុស្សធម៌ផ្សេងៗ" ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមមាត្រា ២ នៃច្បាប់លក្ខន្តិកៈ" [34]។ វាមិនមែនទទួលស្គាល់ថា អាពាហ៍ពិពាហ៍ដោយបង្ខំ ដោយមិនមានវត្តមាននូវឧក្រិដ្ឋកម្មដែលជាប់ទាក់ទងផ្សេងទៀត ពិតជាបង្កើតបានជាអំពើអមនុស្សធម៌នានាដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឡើយ។

---

[29] សំណើ កថាខណ្ឌ ១៩-២២ ។

[30] សៀវភៅរបស់ ANTONIO CASSESE ក្រោមចំណងជើងថា ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (បោះពុម្ពលើកទីពីរ Oxford University Press ២00៨) ទំព័រ ៤១ ("សៀវភៅរបស់ Cassese")។

[31] រដ្ឋអាជ្ញា ទល់នឹង *Kupreskic et al.*, IT-95-16-T, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២000 កថាខណ្ឌ ៥៦៦។

[32] *ដូចយោងខាងលើ* ។

[33] *រដ្ឋអាជ្ញា តទល់ នឹង* Sesay, Kallon, Gbao សំណុំរឿងលេខ SCSL-04-15-T សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ កុម្ភៈ ២00៩ កថាខណ្ឌ ១៦៤ ("ករណី *Sesay*") ។

[34] *ដូចយោងខាងលើ* ។

**៤. អាពាហ៍ពិពាហ៍ដោយបង្ខំមិនបង្កើតបានជាអំពើរំលោភសេពសន្ថវៈ ជាការដាក់មនុស្សជាទាសករផ្លូវភេទ ឬការបង្កអោយមានផ្ទៃពោះដោយបង្ខំ នៅក្រោមមាត្រា ៥ នៃច្បាប់បង្កើត អវតក ឡើយ**

១២. សំណើនេះគឺមិនមានភាពច្បាស់លាស់ជាច្រើន ទាក់ទងនឹងទំនាក់ទំនងរវាងអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ ជាការដាក់មនុស្សជាទាសករផ្លូវភេទ និងការធ្វើអោយមានផ្ទៃពោះដោយបង្ខំ។ អំពើទាំងនេះគឺឧក្រិដ្ឋកម្មផ្សេងៗពីគ្នា ប៉ុន្តែការរំលោភសេពសន្ថវៈ ការដាក់មនុស្សជាទាសករផ្លូវភេទ និងការធ្វើអោយមានផ្ទៃពោះដោយបង្ខំ ត្រូវបានចាត់ចូលជាអនុប្រភេទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ[35]។ ការភ័ន្តច្រលំនេះប្រហែលជាមានចេតនា៖ ម្យ៉ាងដោយសារដើមបណ្តឹងរដ្ឋប្បវេណីកំពុងព្យាយាមកំណត់និយមន័យអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលតាមនេះវាចូលទៅក្នុងយុត្តាធិការរបស់ អវតក ហើយម្យ៉ាងវិញទៀតដោយកំណត់និយមន័យរួមបញ្ចូលគ្នានៃអាពាហ៍ពិពាហ៍ដោយបង្ខំបែបនេះ នាំអោយវាមិនរំលោភបំពានទៅលើវិធាននានាដែលប្រឆាំងនឹងការផ្តន្ទាទោសលើបទល្មើសច្រើនបទ (cumulative conviction)។ ការតម្រូវអោយប្រើការគិតច្រើនហួសប្រមាណដើម្បីជៀសវាងពីភាពផ្ទុយគ្នាដែលមិនមានន័យអ្វីនោះគឺមិនមានភាពសមហេតុផល និងមិនអាចអនុញ្ញាតអោយបានឡើយ។

១៣. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា "តុលាការអន្តរជាតិបានទទួលស្គាល់នូវអាពាហ៍ពិពាហ៍ដោយបង្ខំថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[36]។ ហេតុដូច្នេះ សារៈសំខាន់នៃសំណើនេះប្រហែលជាថាអាពាហ៍ពិពាហ៍ដោយបង្ខំគួរតែត្រូវបានចោទប្រកាន់ជាឧក្រិដ្ឋកម្មដាច់ដោយឡែក ចេញពីអំពើផ្សេងទៀតដូចជា ការរំលោភសេពសន្ថវៈ ឬ ការដាក់អោយធ្វើជាទាសករផ្លូវភេទ ដែលមាននៅក្នុងអំពើដែលរាយរាប់នៅក្នុងបទបញ្ញត្តិច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ប៉ុន្តែ ដោយហេតុថាអាពាហ៍ពិពាហ៍ដោយបង្ខំមិនបង្កើតចូលទៅក្នុងបញ្ជីរាយឈ្មោះអំពើនានា ទាំងនៅក្នុងច្បាប់បង្កើត អវតក ឬ កិច្ចព្រមព្រៀង ដើមបណ្តឹងរដ្ឋប្បវេណី ផ្ទុយទៅវិញ អះអាងថា សម្រាប់ជាគោលបំណងនៃយុត្តាធិការ អាពាហ៍ពិពាហ៍ដោយបង្ខំ អាចបង្កើតបានជាឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈ ការដាក់អោយធ្វើជាទាសករ និង ការធ្វើអោយមានផ្ទៃពោះដោយបង្ខំ ។ ហេតុដូច្នេះ វាក៏ត្រូវបានអះអាងថាស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក ក្រោមមាត្រា ៥ នៃច្បាប់បង្កើត អវតក

---

[35] សំណើ កថាខណ្ឌ ៣១ ។ ដើមបណ្តឹងរដ្ឋប្បវេណីស្នើ កសចស អោយបំពេញ "ការស៊ើបសួរពេញលេញមួយស្តីអំពីឧក្រិដ្ឋកម្មនៃអាពាហ៍ពិពាហ៍ដោយបង្ខំ <u>តួយ៉ាងដូចជា</u> ការរំលោភសេពសន្ថវៈ ការដាក់អោយធ្វើជាទាសករ និង ការធ្វើអោយមានផ្ទៃពោះដោយបង្ខំ" ។

[36] *ដូចយោងខាងលើ* កថាខណ្ឌ៧ ។

ផងដែរ។ ការប៉ុនប៉ងដើម្បីគេចវេសពីប្រភេទនៃយុត្តាធិការដែលគេបង្កើតឡើងនៅក្នុងច្បាប់បង្កើត អវតក ត្រូវតែបដិសេធចោល។ វាមិនជាការសមរម្យចំពោះការអះអាងថា សម្រាប់ជាគោលបំណងនៃយុត្តាធិការ អាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាអំពើរំលោភសេពសន្ថវៈ ការដាក់អោយធ្វើជាទាសករ ឬ ការធ្វើអោយមានផ្ទៃពោះដោយបង្ខំ អញ្ចឹងហើយត្រូវបានគេអះអាងថាស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក ប៉ុន្តែព្យាយាមចុងក្រោយសុំអោយអនុវត្តនូវការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់អាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាឧក្រិដ្ឋកម្មដាច់ដោយឡែកដោយខ្លួនឯងយល់ឃើញនោះ។ អំពើតែមួយដដែលអាចមិនត្រូវបានផ្លាស់ប្តូរពីឧក្រិដ្ឋកម្មមួយ ទៅឧក្រិដ្ឋកម្មមួយទៀត ដោយផ្អែកទៅលើការពិនិត្យដែលកំពុងត្រូវបានគេធ្វើឡើង។ ការវាយតម្លៃលើយុត្តាធិការ និងភាពអនុវត្តបាននៃច្បាប់សារធាតុ ត្រូវតែធ្វើឡើងដោយឈរលើមូលដ្ឋាននៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់តែមួយដូចគ្នា។

១៨. អាពាហ៍ពិពាហ៍ដោយបង្ខំ មិនបានរួមបញ្ចូលជាចាំបាច់នូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ ការដាក់អោយធ្វើជាទាសករ និង ការធ្វើអោយមានផ្ទៃពោះដោយបង្ខំ ឡើយ។ ថ្វីបើ ដើមបណ្តឹងរដ្ឋប្បវេណីគូសបញ្ជាក់ថា អាពាហ៍ពិពាហ៍ដោយបង្ខំ "អាចរួមបញ្ចូល" ឬមានជាប់ពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្ម[37]ដទៃទៀតក៏ដោយ ក៏ឧក្រិដ្ឋទាំងនេះមិនមែនជាលទ្ធផលដែលមិនអាចជៀសផុតបាននៃអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។ តាមពិតសម្រាប់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន ឧក្រិដ្ឋកម្មនៃអាពាហ៍ពិពាហ៍ដោយបង្ខំជាបទល្មើសដែលមិនពាក់ព័ន្ធនឹងផ្លូវភេទ[38]។ ហេតុដូច្នេះ ហេតុដែលថាក្នុងឱកាសមួយចំនួន អាពាហ៍ពិពាហ៍ដោយបង្ខំអាចនាំអោយអោយកើតមានឧក្រិដ្ឋកម្មទាំងនេះ មិនអនុញ្ញាតអោយធ្វើការបញ្ចូលនូវ អាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយនៅក្នុងយុត្តាធិការរបស់ អវតក ឡើយ។

១៩. ម្យ៉ាងវិញទៀត ប្រសិនបើជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទអាពាហ៍ពិពាហ៍ដោយបង្ខំ និងបន្ថែមពីលើការរំលោភលើផ្លូវភេទ, ការធ្វើឲ្យទៅជាទាសករ ឬ ការធ្វើឲ្យមានគភ៌ដោយបង្ខំចំពោះបទល្មើសដូចគ្នា នោះនឹងរំលោភលើវិធានស្តីពី ការផ្តន្ទាទោសលើបទល្មើសច្រើនបទ

---

[37] សំណើ កថាខណ្ឌ ៦ ។

[38] *រដ្ឋអាជ្ញា តទល់ នឹង Brima, Kamara, and Kanu* សំណុំរឿងលេខ SCSL-04-16-A សាលដីការបស់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២២ កុម្ភៈ ២០០៨ កថាខណ្ឌ ១៨១ និង ១៩៦ ("សាលដីកា AFRC") ។

(cumulative conviction)។ មានតេស្តសំខាន់ចំនួនប្រាំ ដែលត្រូវបានប្រើប្រាស់ដោយតុលាការអន្តរជាតិ និងតុលាការជាតិ ដើម្បីកំណត់ថាតើការផ្តន្ទាទោសត្រួតគ្នា ត្រូវបានអនុញ្ញាតដែរ ឬទេ[39] ហើយតេស្តមួយចំនួនក្នុងចំណោមតេស្តទាំងនេះ អាចរំលោភទៅលើសិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទ[40]។ កសចស ធ្លាប់បានសម្រេចលើបញ្ហានេះថា ការផ្តន្ទាទោសលើបទល្មើសច្រើនបទ (cumulative conviction) អាចធ្វើទៅបាន ដរាបណា "បទល្មើសអន្តរជាតិនីមួយៗទាំងនេះមានធាតុផ្សំខុសគ្នាយ៉ាងច្បាស់ ដែលមិនមាននៅក្នុងបទល្មើសមួយទៀត ហើយការពារតម្លៃផ្សេងៗគ្នា[41]។ ធាតុផ្សំមួយគឺខុសគ្នាយ៉ាងច្បាស់ពីធាតុផ្សំមួយផ្សេងទៀត ប្រសិនបើវាត្រូវការភស្តុតាងរបស់អង្គហេតុមួយ ដែលមិនត្រូវការដោយធាតុផ្សំមួយផ្សេងទៀត[42]។ ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានគូសបញ្ជាក់ ថាតើបទល្មើសទាំងនេះមានធាតុផ្សំខុសគ្នាយ៉ាងច្បាស់ ដែលមិនមាននៅក្នុងបទល្មើសផ្សេងទៀត[43]។ ប្រសិនបើបទល្មើសទាំងអស់នោះពិតជាមានធាតុផ្សំដាច់ដោយឡែកពីបទល្មើសរំលោភលើផ្លូវភេទ, ការធ្វើឱ្យទៅជាទាសករ ឬ ការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំទេ នោះបទល្មើសទាំងនោះ មិនស្ថិតនៅក្រោមយុត្តាធិការរបស់ អវតក ស្របតាមមាត្រា ៥ ថាជាបទល្មើសមួយក្នុងចំណោមបទល្មើសទាំងនោះឡើយ។ ប្រសិនបើបទល្មើសទាំងនោះមិនមានធាតុផ្សំដាច់ដោយឡែកទេ បទល្មើសទាំងនោះរំលោភវិធានប្រឆាំងនឹង ការផ្តន្ទាទោសលើបទល្មើសច្រើនបទ (cumulative conviction)។ ទោះជាយ៉ាងក៏ដោយ ក៏បទល្មើសទាំងនេះមិនត្រូវបានចោទប្រកាន់នៅ អវតក ដែរ។

---

[39] តេស្តទាំងនេះរួមមាន "រឿងក្តី *Akayesu* ការធ្វើតេស្តលើធាតុផ្សំ ឬ ផលប្រយោជន៍ខុសគ្នាៗ", រឿងក្តី *Tadić* ការធ្វើតេស្តលើការប្រព្រឹត្តដែលមានទោសទាំងស្រុង", រឿងក្តី "*Čelebići* ការធ្វើតេស្តលើធាតុផ្សំអន្តោម័តពីរ(២)ដាច់ពីគ្នា" (Two-Prong Materially Distinct Element Test) និងការធ្វើតេស្ត "Judges Hunt and Bennouna's Substantive Distinct Element Test " ។

[40] ករណីរបស់ អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អបជ០៣) សំណើរបស់អៀង សារី ស្របតាមសេចក្តីសម្រេចលើសំណើជាបន្ទាន់របស់មេធាវីការពារក្តី ស្នើសុំបន្ថែមពេលវេលាសមស្របដើម្បីដាក់សារណាជំទាស់តវ៉ាទៅលើបញ្ហាយុត្តាធិការ ចុះថ្ងៃទី៧ ខែ មេសា ឆ្នាំ ២០០៨, កថាខណ្ឌ ។

[41] ករណីរបស់ អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៩។

[42] *ករណីព្រះរាជអាជ្ញា តទល់ជាមួយ Delalić* និងអ្នកផ្សេងទៀត IT-96-21-A សាលដីកាអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២០ ខែ កុម្ភៈ ២០០១ កថាខណ្ឌ ៤១២ ។

[43] កថាខណ្ឌទី ១៥ នៃសំណើ ។

១៦. តាមច្បាប់លក្ខន្តិកៈបង្កើត ICC ការធ្វើឱ្យទៅជាទាសករមានន័យថា "ការប្រើអំណាចណាមួយ ឬអំណាចទាំងអស់ដែលមានជាប់នឹងសិទ្ធិលើកម្មសិទ្ធិលើបុគ្គលម្នាក់ និងរួមទាំងការប្រើប្រាស់សិទ្ធិនេះក្នុងដំណើរការជួញដូរមនុស្ស"[44]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") បានបំភ្លឺនិយមន័យនេះ ដោយពន្យល់បញ្ចុះបញ្ចូលនូវធាតុផ្សំមួយកំផ្ដែនៅក្នុងរឿងក្ដី *Kunarac* និងអ្នកផ្សេងទៀត[45]។ និយមន័យនេះហាក់ដូចជាមិនរាប់បញ្ចូលនូវធាតុផ្សំចំណងអាពាហ៍ពិពាហ៍របស់បទល្មើស អាពាហ៍ពិពាហ៍ដោយបង្ខំទេ។

១៧. តាមការកំណត់និយមន័យនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ការរំលោភលើផ្លូវភេទ គឺបង្កឡើងដោយ "ការឈ្លានពានលើរូបរាងកាយដែលមានចរិតផ្លូវភេទ ដែលប្រព្រឹត្តឡើងក្រោមកាលៈទេសៈដែលមានលក្ខណៈបង្ខំ"[46] ។ តែ និយមន័យនេះហាក់ដូចជាមិនរាប់បញ្ចូលនូវធាតុផ្សំនៃបទល្មើសអាពាហ៍ពិពាហ៍ដោយបង្ខំដែរ។

១៨. ចៅក្រមបានព្យាយាមញែកឱ្យដាច់ចេញពីគ្នារវាងបទល្មើសទាសករផ្លូវភេទ និងការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំ។ ខណៈដែលអាពាហ៍ពិពាហ៍ដោយបង្ខំអាចពាក់ព័ន្ធជាមួយសមាសភាពរបស់បទល្មើសរំលោភលើផ្លូវភេទ អំពើហិង្សាលើផ្លូវភេទ និងការធ្វើឱ្យទៅជាទាសករ ប៉ុន្តែក៏មិនអាចកំណត់ពីអត្តិភាពរបស់វាបានដែរ។ ធាតុផ្សំដ៏សំខាន់របស់បទល្មើសអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជំងឺបាក់ស្បាតខាងស្មារតី និងសីលធម៌ ដែលបង្កឡើងដោយការដាក់កាតព្វកិច្ចនៃចូលរួមគ្នាលក្ខណៈប្ដី-ប្រពន្ធដោយបង្ខំ ដែលប្រព្រឹត្តឡើងដោយជនល្មើសទៅលើជនរងគ្រោះ[47] តាមរយៈការគំរាមកំហែង ឬដោយការបង្ខំដែលកើតចេញពីពាក្យសំដីរបស់ជនល្មើស ឬការប្រព្រឹត្តតាមរូបភាពដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូលរបស់ SCSL បានសម្រេចថា អាពាហ៍ពិពាហ៍ដោយបង្ខំ

---

[44] ច្បាប់លក្ខន្តិកៈ ICC មាត្រា ៧(២)(គ)។

[45] *រឿងក្ដីរវាងព្រះរាជអាជ្ញា តទល់ជាមួយ Kunarac និងអ្នកផ្សេងទៀត* IT-96-23 & 23/1 សាលក្រមចុះថ្ងៃទី ២២ ខែ កុម្ភៈ ២០០១, សូមមើលកថាខណ្ឌ ៥៤២-៥៤៣០: "តាមនិយមន័យនេះ ការបង្ហាញពីការធ្វើឱ្យទៅជាទាសកររួមមានធាតុផ្សំនៃការត្រួតត្រា និងម្ចាស់កម្មសិទ្ធិ, ការរឹតត្បិត ឬ ការត្រួតត្រាលើស្វ័យភាព សេរីភាពនៃការជ្រើសរើស ឬ សេរីភាពនៃការដើរហើររបស់បុគ្គល ហើយជាញឹកញាប់ ជនល្មើសទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន។ ពុំមានការយល់ព្រមពីជនរងគ្រោះទេ ។

[46] *រឿងក្ដីរវាងព្រះរាជអាជ្ញា តទល់ជាមួយ Akayesu* ICTR-96-4-T សាលក្រមចុះថ្ងៃទី ២ ខែ កញ្ញា ១៩៩៨ កថាខណ្ឌ ៥៩៨ ។

[47] *រឿងក្ដីរវាងព្រះរាជអាជ្ញាតទល់ជាមួយ Brima, Kamara, and Kanu,* SCSL-04-16-T, សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានការស្វែងយោបល់គ្នាមួយផ្នែកដោយចៅក្រម Justice Doherty ចុះថ្ងៃទី ២០ ខែ មិថុនា ២០០៧ កថាខណ្ឌ ៥២-៥៣ ។

គឺជាបទល្មើសដាច់ដោយឡែក ហើយមិនស្ថិតនៅក្រោមដំបូលនៃបទល្មើសទាសករផ្លូវភេទទេ[48]។ អង្គជំនុំជម្រះ នេះទទួលស្គាល់បន្ថែមទៀតថា នៅក្នុងច្បាប់អន្តរជាតិ អាពាហ៍ពិពាហ៍ដោយបង្ខំ បង្កើតបានជាបទល្មើសអន្តរជាតិដាច់ដោយឡែកមួយ[49]។ អាស្រ័យហេតុនេះ អាពាហ៍ពិពាហ៍ ដោយបង្ខំមិនស្ថិតនៅក្រោមលក្ខណៈ វិនិច្ឆ័យរបស់មាត្រា ៥ នៃច្បាប់បង្កើត អវតក ឡើយ។

១៩. ការធ្វើឱ្យមានគភ៌ដោយបង្ខំមិនបានចែងនៅក្នុងមាត្រា ៥ នៃច្បាប់បង្កើត អវតក ឡើយហើយ អាស្រ័យហេតុនេះ បើទោះបីជាអាពាហ៍ពិពាហ៍ដោយបង្ខំស្ថិតនៅក្រោមជំពូកនេះ វាប្រហែលជា មិនអាចអនុវត្តនៅ អវតក បានដែរ។ បទល្មើសនេះមិនត្រូវបានកំណត់និយមន័យដោយយុត្តិសាស្ត្រ អន្តរជាតិនៅឡើយទេ។ បទល្មើសនេះ គឺជាបទល្មើសមួយដែលត្រូវបានកំណត់នៅក្នុងនិយមន័យ របស់ ICC ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[50]ដែលត្រូវបានទទួលយកដោយកិច្ចព្រមព្រៀង[51]។ ប៉ុន្តែបើពិនិត្យមើលធាតុផ្សំបទល្មើសក្រោមច្បាប់លក្ខន្តិកៈ ICC, ធាតុផ្សំរបស់បទល្មើសនេះនៅក្នុង ឆ្នាំ ១៩៩៨ គឺ២០ឆ្នាំ បន្ទាប់ពីកម្ពុជាប្រជាធិបតេយ្យ ចែងដូចខាងក្រោម៖

---

[48] សាលដីកាក្នុងរឿងក្តី AFRC ។ អង្គជំនុំជម្រះតុលាការកំពូលរកឃើញភាពខុសគ្នារវាងអាពាហ៍ពិពាហ៍ដោយបង្ខំ និង ទាសករផ្លូវភេទ និងសន្និដ្ឋានថា“(...) នៅក្នុងបរិបទជម្លោះនៅប្រទេសសៀរ៉ាឡេអូន អាពាហ៍ពិពាហ៍ដោយបង្ខំពិពណ៌នាពីស្ថានភាពមួយ ដែលតាមពាក្យសំដី ឬ ការប្រព្រឹត្តរបស់ជនល្មើស ឬ ពាក្យសំដីរបស់អ្នកដែលទទួលខុសត្រូវ ចាប់បង្ខំជនណាម្នាក់ដោយបង្ខំ ដោយគំរាមកំហែង ដើម្បីធ្វើជាសហព័ន្ធ ដែលបង្កឱ្យមានការឈឺចាប់ជាទម្ងន់ទាំងរូបកាយ ឬ ស្មារតីដល់ជនរងគ្រោះ” នៅកថាខណ្ឌ ១៨៣។ សូមមើលផងដែរនូវស្នាដៃរបស់ Neha Jain “អាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិៈ បញ្ហានៃនិយមន័យ និង ការកាត់សេចក្តី, 6 J. INT'L CRIM. JUST. 1013, 1021 (2008): “អង្គជំនុំជម្រះតុលាការកំពូលក៏បានញែកឱ្យដាច់ចេញពីគ្នារវាងបទល្មើសអាពាហ៍ពិពាហ៍ដោយបង្ខំ និងទាសករផ្លូវភេទ ដោយផ្អែកលើមូលហេតុថា ខណៈ អាពាហ៍ពិពាហ៍ដោយបង្ខំអាចពាក់ព័ន្ធជាមួយអំពើលើផ្លូវភេទដោយគ្មានការយល់ព្រម និងការដកហូតនូវសិទ្ធិសេរីភាព (ធាតុផ្សំរបស់ទាសភាពផ្លូវភេទ) ពួកវាមានធាតុផ្សំបន្ថែមៈ ការធ្វើជាសព័ន្ធដោយបង្ខំដែលបណ្តាលឱ្យមានការឈឺចុកចាប់ជាទម្ងន់ដល់រូបរាងកាយ និងស្មារតី និងទំនាក់ទំនងរវាង “សព័ន្ធ” ជាមួយនឹងប្រតិឃាតវិន័យចំពោះការរំលោភបំពានលើការផ្សំផ្គុំ នេះមានន័យថា អាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសផ្លូវភេទឡើយ ខុសពីទាសភាពផ្លូវភេទ” ។

[49] Micaela Frulli ការវិវឌ្ឍន៍ទៅមុខរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិៈ តុលាការពិសេសសៀរ៉ាឡេអូនទទួលស្គាល់អាពាហ៍ពិពាហ៍ដោយបង្ខំ ថាជា “ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថ្មី” 6 J. INT'L CRIM. JUST. 1033, 1036 (2008): “ប៉ុន្តែ ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានអនុវត្តជាច្រើនដោយសៀរ៉ាឡេអូន មិនត្រូវពិពណ៌នាពេញលេញដោយអំពើតែមួយដែលមានចែងនៅក្នុងច្បាប់លក្ខន្តិកៈ SCSL ។ អាពាហ៍ពិពាហ៍ដោយបង្ខំ គឺលើសពីសមាសភាពរបស់វា” ។ សូមមើលផងដែរ Monika Satya Kalra “អាពាហ៍ពិពាហ៍ដោយបង្ខំៈ ការបង្ហាញបង្កើនឱ្យដឹងពីភាពសំងាត់របស់ Rwanda, *Rwanda's Secret Revealed*, 7 U.C. DAVIS J. INT'L L. & POL'Y 197, 215 (2001).

[50] ច្បាប់លក្ខន្តិកៈ ICC មាត្រា ៧(១)(ច)(៤)។

[51] កិច្ចព្រមព្រៀង មាត្រា ៩ ។

១. ជនដែលបានបង្ខាំងស្ត្រីម្នាក់ ឬ ច្រើននាក់ដោយធ្វើឱ្យមានផ្ទៃពោះដោយបង្ខំ ក្នុងចេតនាចង់ឱ្យមានប៉ះពាល់ដល់សមាសភាពរបស់ក្រុមជាតិពន្ធុនៃប្រជាជាតិណាមួយ ឬ ដោយអនុវត្តអំពើរំលោភបំពានធ្ងន់ធ្ងរដទៃទៀតលើច្បាប់អន្តរជាតិ។

២. អំពើត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារទូទៅ ឬជាប្រព័ន្ធសំដៅប្រឆាំងទៅលើជនស៊ីវិល។

៣. ជនដែលដឹងថា ការប្រព្រឹត្តរបស់ខ្លួនជាផ្នែកមួយ ឬ មានបំណងឱ្យអំពើរបស់ខ្លួន ជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬ ជាប្រព័ន្ធ សំដៅប្រឆាំងនឹងជនស៊ីវិល[52]។

២០. និយមន័យនៃការធ្វើឱ្យមានគត៌ដោយបង្ខំនេះ ហាក់ដូចជាមិនបានបញ្ចូលធាតុផ្សំនៃអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ។ អាពាហ៍ពិពាហ៍ដោយបង្ខំ ក៏មិនត្រូវការចេតនាមួយដើម្បីបំផ្លែងសមាសភាពជាតិពន្ធុរបស់ប្រជាជនណាមួយដែរ។ អាស្រ័យហេតុនេះ អាពាហ៍ពិពាហ៍ដោយបង្ខំមិនស្ថិតនៅក្រោមយុត្តាធិការរបស់ អវតក ដោយផ្អែកលើការធ្វើឱ្យមានគភ៌ដោយបង្ខំឡើយ។

**ខ. អាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់កម្ពុជា ឬ ច្បាប់ទម្លាប់អន្តរជាតិ ដែលចងកាតព្វកិច្ចកម្ពុជានៅឆ្នាំ ១៩៧៥-៧៩ នោះឡើយ**

២១. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានអះអាងនៅក្នុងសំណើថា អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាបទល្មើសមួយដែលបញ្ញត្តិដោយច្បាប់កម្ពុជានៅឆ្នាំ ១៩៧៥-៧៩ ។ មូលដ្ឋានតែមួយគត់ដើម្បីដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងឡាយណាដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅឆ្នាំ១៩៧៥-៧៩ គឺច្បាប់ទម្លាប់អន្តរជាតិ ដែលអាចបង្កើតបានតាមរយៈ ទម្លាប់អនុវត្តជាទូទៅ និង ស៊ីសង្វាក់គ្នារបស់រដ្ឋ និង ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ (opinio juris) តែប៉ុណ្ណោះ[53] ។

២២. អនុលោមតាមដើមបណ្តឹងរដ្ឋប្បវេណី "តុលាការអន្តរជាតិទទួលស្គាល់អាពាហ៍ពិពាហ៍ដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[54]។ ការលើកឡើងបែបនេះ គឺមិនត្រឹមត្រូវ។ អាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានទទួលស្គាល់ដោយតុលាការចំរុះ (hybrid) តែមួយគត់ (មិនមែនជាតុលាការអន្តរជាតិពេញលេញទេ) នោះគឺតុលាការ SCSL[55] តុលាការមួយនេះមានយុត្តាធិការលើឧក្រិដ្ឋ

---

[52] ច្បាប់លក្ខន្តិកៈ ICC មាត្រា ៧(១)(ច)(៤) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើឱ្យមានគភ៌ដោយបង្ខំ ICC-ASP/1/3។

[53] ចម្លើយតបស្តីពីការបាត់ខ្លួនដោយបង្ខំ កថាខណ្ឌ ២២-២៣ ។

[54] សំណើសុំ កថាខណ្ឌ ៧ ។

[55] សាលដីកាករណី AFRC កថាខណ្ឌ ១៧៥-២០២។ *រឿងក្តី Sesay* កថាខណ្ឌ ១៦៤។

កម្មទាំងឡាយដែលត្រូវបានគេប្រព្រឹត្តឡើង "ក្នុងដែនដីរបស់ប្រទេសសៀរ៉ាឡេអូន ចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦"[56]។ អាស្រ័យហេតុនេះ ការសម្រេចណាមួយដោយតុលាការនោះដែលថា អាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់ទម្លាប់អន្តរជាតិ អនុវត្ត ចំពោះតែឧក្រិដ្ឋកម្មទាំងឡាយណាដែលត្រូវបានគេប្រព្រឹត្តក្រោយពេលនោះ។ ឧក្រិដ្ឋកម្មដែលត្រូវ បានចោទប្រកាន់នេះ មិនអាចអនុវត្តជាប្រតិសកម្មចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានគេប្រព្រឹត្ត នៅឆ្នាំ ១៩៧៥-៧៩ បានឡើយ។ ដូចមេធាវីការពារក្ដីធ្លាប់បានពន្យល់រួចមកហើយ ច្បាប់មួយមិន អាចមានប្រតិសកម្មបង្កើតបទល្មើសព្រហ្មទណ្ឌ ឬទម្រង់នៃការទទួលខុសត្រូវមួយដែលតាមរយៈ នោះបទល្មើសនោះអាចត្រូវបានគេប្រព្រឹត្ត ដោយហេតុថាប្រសិនបើយ៉ាងដូច្នេះមែន វានឹងរំលោភ *គោលការណ៍គ្មានទោសបើគ្មានច្បាប់ចែង*[57] (*nullum crimen sine lege* ) ។ ដើម្បីអនុវត្តអាពាហ៍ ពិពាហ៍ដោយបង្ខំប្រឆាំងនឹងជនត្រូវចោទទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២ ចំពោះឧក្រិដ្ឋកម្ម ទាំងឡាយដែលត្រូវបានគេប្រព្រឹត្តនៅឆ្នាំ១៩៧៥-៧៩ លុះត្រាតែឧក្រិដ្ឋកម្មទាំងនោះត្រូវតែបានគេ ចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ ច្បាប់ កម្ពុជានៅឆ្នាំ ១៩៧៥-៧៩។ តែករណីនេះមិនមែនអញ្ចឹងទេ។

២៣. អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានបង្កើតឡើងថាជាឧក្រិដ្ឋកម្មអន្តរជាតិជាលើកដំបូងដោយ SCSL នៅក្នុងសវនាការរឿងក្ដី AFRC[58]។ តាមពិត អាពាហ៍ពិពាហ៍ដោយបង្ខំ "មិនដែលត្រូវបានទទួល ស្គាល់ ឬ កំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដាច់ដោយឡែកនៅមុនឆ្នាំ ២០០៤ នោះទេ នៅពេលដែលតុលាការពិសេសសៀរ៉ាឡេអូន ក្លាយជាតុលាការឧក្រិដ្ឋកម្មសង្គ្រាមដំបូងគេបង្អស់ ដែលបានចោទប្រកាន់ជនជាប់ចោទពីបទល្មើសអាពាហ៍ពិពាហ៍ដោយបង្ខំ"[59]។ ម្យ៉ាងទៀត "ពុំមាន តុលាការអន្តរជាតិដទៃទៀតបានជំនុំជម្រះលើភស្តុតាង នៃបទល្មើសអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយដាក់ការចោទប្រកាន់នេះចូលទៅក្នុងករណីលើកលែង ដោយមិនពិចារណាថាជាវិធាននោះ

---

[56] ច្បាប់លក្ខន្តិកៈ SCSL មាត្រា ១។

[57] សូមមើលចម្លើយតបស្ដីពីការបាត់ខ្លួនដោយបង្ខំ កថាខណ្ឌ ២១ ។

[58] Jain, ខាងលើ, កំណត់សំគាល់លេខ ៤៨ នៅ ១០១៤។ សូមមើលផងដែរ Frulli, ខាងលើ, កំណត់សំគាល់លេខ ៤៨ នៅ ១០១៤ ។

[59] Michael Scharf & Suzanne Mattler *អាពាហ៍ពិពាហ៍ដោយបង្ខំៈ ការពិនិត្យលើភាពអាចសម្រេចបានរបស់តុលាការ ពិសេសសៀរ៉ាឡេអូនលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថ្មី (Forced Marriage: Exploring the Viability of The Special Court for Sierra Leone's New Crimes Against Humanity)* ការស្រាវជ្រាវលើសំណុំរឿង ។ ឯកសារស្រាវជ្រាវលេខ ០៥-៣៥ ខែ តុលា ឆ្នាំ ២០០៥។

ទេ”[60]។

២៤. តាមពិត សំអាងហេតុនៅក្នុងសាលដីកាវឿងក្តី AFRC ដែលទទួលស្គាល់អាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាអំពើអមនុស្សធម៌មួយ ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺពិតជាពុំមានហេតុផល ទាល់តែទេ។ អង្គជំនុំជម្រះរបស់តុលាការកំពូលនៅក្នុងរឿងក្តី AFRC គ្រាន់តែយល់ឃើញថា អាពាហ៍ពិពាហ៍ដោយបង្ខំ បង្កើតបានជាអំពើអមនុស្សធម៌នៅក្រោមច្បាប់លក្ខន្តិកៈ SCSL ហើយ អំពើអមនុស្សធម៌ផ្សេងៗទៀតគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយអាស្រ័យហេតុ នេះ អាចមានមូលដ្ឋានដើម្បីឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ[61]។ វាមានលក្ខណៈជាក់ ច្បាស់អំពីកំហុសដែលមានក្នុងភាពសមហេតុផលនេះ ។ បើគិតពីការសន្និដ្ឋានដ៏សមហេតុផលលើ អំណះអំណាងនេះ មានន័យថា ការវិវឌ្ឍន៍បន្តបន្ទាប់របស់ច្បាប់ដែលបានបង្កើនចំនួននៃបទល្មើស ព្រហ្មទណ្ឌ ជាពិសេសក្នុងប្រភេទដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នឹងនាំឲ្យអនុវត្តជា ប្រតិសកម្មនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសទាំងនោះ ដរាបណាពួកវាស្ថិតនៅ ក្នុងក្រុមប្រភេទនេះ។ ករណីនេះបានធ្វើអោយការការពារក្រោមគោលការណ៍*គ្មានបទល្មើសបើគ្មាន ច្បាប់ចែង nullum crimen sine lege* ប្រែទៅជាគ្មានន័យ។

២៥. សាលដីកានៅក្នុងរឿងក្តី AFRC ក៏មិនបានបកស្រាយថាតើអាពាហ៍ពិពាហ៍ដោយបង្ខំបានក្លាយជា ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលណាទេ។ ការណ៍ដែលថាអាពាហ៍ពិពាហ៍ដោយបង្ខំស្ថិតនៅ ក្រោមយុត្តាធិការរបស់ SCSL នៅឆ្នាំ២០០៨ ហើយត្រូវបង្កើតទៅជាបទល្មើសព្រហ្មទណ្ឌនៃអំពើ អមនុស្សធម៌ នៅពេលមួយបន្ទាប់ពីការចាប់ផ្តើមនៃយុត្តាធិការពេលវេលារបស់តុលាការនេះ ក៏ មិនបានដោះស្រាយចំណោទដែលថា តើវាក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលណា។ ពុំ មានអនុសញ្ញាអន្តរជាតិណាកំណត់អាពាហ៍ពិពាហ៍ដោយបង្ខំថាជាអំពើខុសច្បាប់ឡើយ ហើយក៏ មិនមានយុត្តាធិការជាតិណាមួយដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអាពាហ៍ពិពាហ៍ដោយ បង្ខំ ឬ បានសំអាងលើតុលាការ SCSL នោះដែរ។ ធម្មតាដោយសារតែមានប្រទេសជាច្រើនទទួល ស្គាល់ថា អាពាហ៍ពិពាហ៍តាមការផ្សំផ្គុំ ឬ អាពាហ៍ពិពាហ៍ដោយបង្ខំជាផ្នែកមួយដែលអាចទទួល យកបានក្នុងសង្គមមនុស្ស បើទោះបីជាគោលគំនិតនេះផ្ទុយនឹងតម្លៃរបស់បស្ចិមប្រទេសក៏

---

[60] Amy Palmer, *An Evolutionary Analysis of Gender-Based War Crimes and the Continued Tolerance of "Forced Marriage"*, 7 NW. U. J. INT'L HUM. RTS. 128, 137 (2009)

[61] សាលដីកាក្នុងរឿងក្តី AFRC កថាខណ្ឌទី ១៩៨ ។

ដោយ[62]។ ជាក់ស្តែង អាពាហ៍ពិពាហ៍ដោយបង្ខំមិនទាន់បានក្លាយជាបទល្មើសព្រហ្មទណ្ឌក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-៧៩ ទេ។

**គ. កសចស គ្មានកាតព្វកិច្ចស៊ើបអង្កេតទៅលើអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ**

២៦. បើទោះបីជាអាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ ក៏គេមិនអាចសម្រេចដោយស្វ័យប្រវត្តិថា មានកាតព្វកិច្ចចាំបាច់ដើម្បីផ្តន្ទាទោសបទល្មើសបែបនោះបានទេ។ ទម្ងន់នៃយោបល់របស់អ្នកស្រាវជ្រាវជាន់ខ្ពស់ហាក់បង្ហាញថា ពុំមានកាតព្វកិច្ចផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ[63]។

---

[62] យោងទៅតាមអត្ថបទស្រាវជ្រាវដោយមជ្ឈមណ្ឌលច្បាប់បរិស្ថាន Environmental Law Center "នៅក្នុងរឿងក្តីចាប់ពីអាមេរិចខាងត្បូង ដល់រ៉ូម៉ាំងកាតូលិក ភ័ព្វព្រេងវាសនាគឺពាក់ពាក់នឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជំនឿក្នុង Orthodox Jewish អនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំ និងអាពាហ៍ពិពាហ៍ដោយការផ្សំផ្គុំ។ ស្រដៀងគ្នា អាពាហ៍ពិពាហ៍ដោយបង្ខំគឺជាផ្នែកមួយនៃសាសនាសម័យទំនើបរបស់ពិភពលោក" ។ *សូមមើល* អង្គភាពស្រាវជ្រាវ ELC *តើអាពាហ៍ពិពាហ៍ដោយបង្ខំ ឬដោយការផ្សំផ្គុំជាការរំលោភលើសិទ្ធិមនុស្ស ឬការអនុវត្តបែបវប្បធម៌ដែលមានតម្លៃមួយដែលលើកស្ទួយភាពជាប់ស្អិតរមួតនៃសង្គម?* អាពាហ៍ពិពាហ៍ដោយបង្ខំ ជាពិសេស គឺមានលក្ខណៈធម្មតានៅក្នុងប្រទេសឥណ្ឌា ដែលនៅទីនោះ "ភាគរយច្រើនបំផុតនៃអាពាហ៍ពិពាហ៍ ... ត្រូវបានគេផ្សំផ្គុំឡើង ហើយទំនៀមទម្លាប់នៃអាពាហ៍ពិពាហ៍តាមការផ្សំផ្គុំគឺជាបង្កើតឡើងដោយស្របច្បាប់"។ *សូមមើល* Binaya Kumar Bastia *ទិដ្ឋភាពអន្តរសង្គមនៃការអនុវត្តទាក់ទងផ្លូវភេទ និងបទល្មើសផ្លូវភេទ* - ទិដ្ឋភាពមកពីប្រទេសឥណ្ឌា 13 J. CLIN. FORENSIC MED. 208, 210 (2006)។

[63] Roman Boed, ឥទ្ធិពលនៃការលើកលែងទោសក្នុងស្រុកទៅលើសមត្ថភាពនៃរដ្ឋបរទេស ដើម្បីផ្តន្ទាទោសរដ្ឋអាជ្ញាចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ (*The Effect of a Domestic Amnesty on the Ability of Foreign States to Prosecute Alleged Perpetrators of Serious Human Rights Violations*), 33 CORNELL INT'L L.J. 297, 314-18 (2000) (ពុំមានកាតព្វកិច្ច); Claudia Angermaier,។ *The ICC* និងការលើកលែងទោស: តើតុលាការអាចសម្របសម្រួលឱ្យមានគំរូយុត្តិធម៌មួយបែបស្តាបនាឡើងវិញបានទេ (*Can the Court Accommodate a Model of Restorative Justice?*), 1 EYES ON THE ICC 131, 140 (2004) (ពុំមានកាតព្វកិច្ច)។ Michael Scharf, *From the Exile Files:* ការសាកល្បងទៅលើការធ្វើពាណិជ្ជកម្មយុត្តិធម៌ដើម្បីសន្តិភាព (*an Essay on Trading Justice for Peace,*), 63 WASH. & LEE L. REV. 339, 364-367 (2006): "ដូច្នេះ ពុំមានអ្វីដែលត្រូវឆ្ងល់នោះទេថា សហគមន៍អន្តរជាតិបានទទួលស្គាល់ថាការហាមឃាត់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាត់ទុកជាវិធានដាច់ខាតមួយ (a *jus cogens* norm)។ នេះមិនមែនមានន័យថា កាតព្វកិច្ចភ្ជាប់មកជាមួយដើម្បីផ្តន្ទាទោស ទទួលបានឋានៈប្រហាក់ប្រហែលគ្នានោះទេ។ តាមពិតទៅភស្តុតាងទាំងអស់ គឺផ្ទុយគ្នា"។ Christine A. E. Bakker, *A Full Stop to Amnesty in Argentina*, 3 J. INT'L CRIM. JUST. 1106, 1114 (2005): "ដោយសារអញ្ញត្រកម្មខ្លះ នោះវាជាការពិតដែលថា ទាំងតុលាការជាតិ និងទាំងតុលាការ

២៧. ឧបមាថា មានកាតព្វកិច្ចផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នោះកាតព្វកិច្ចនេះមិនធ្លាក់ទៅលើ កសចស ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីអះអាងនោះទេ[64] ប៉ុន្តែវាធ្លាក់ទៅលើរាជរដ្ឋាភិបាលកម្ពុជា ("RCG") ទៅវិញទេ។ នៅក្នុងសង្គមប្រជាធិបតេយ្យ "បទល្មើសព្រហ្មទណ្ឌត្រូវបានបង្កើតឡើងយ៉ាងច្បាស់ដោយនីតិប្រតិបត្តិ។ តុលាការខ្លួនឯងផ្ទាល់មិនអាចកំណត់ពីអត្ថិភាពនៃបទល្មើសថ្មីស្រឡាងមួយ (*de novo*) ដែលមិនមានចែងនៅក្នុងច្បាប់ដែលប្រកាសឱ្យប្រើដោយនីតិប្រតិបត្តិនោះទេ"[65]។

២៨. លើសពីនេះទៅទៀត ដូចដែលអាចឃើញនៅក្នុងយុត្តិសាស្ត្ររបស់ ICTY ទាក់ទងទៅនឹងការកែប្រែដីកាចោទប្រកាន់ កាតព្វកិច្ចតាមការសន្មតដើម្បីចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម អាចត្រូវបានលុបបំបាត់ដោយកត្តាផ្សេងទៀត។ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើរបស់អយ្យការ សុំអោយបន្ថែមបទចោទទៅក្នុងដីកាចោទប្រកាន់ដែលមានស្រាប់ ដែលការធ្វើបែបនោះអាច "នាំឱ្យមានខាតបង់ដោយអយុត្តិធម៌ចំពោះជនជាប់ចោទ"[66]។

---

អន្តរជាតិ ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវច្បាប់ជាច្រើនរូប នៅតែស្ទាក់ស្ទើរក្នុងការទទួលយកអត្ថិភាពនៃវិធានដាច់ខាត (*jus cogens* norm) ឬនិយាយពីការមន្ទិលសង្ស័យអំពីខ្លឹមសារជាក់ស្តែង និងការអនុវត្តវិធានទាំងនោះ។ ខ្លឹមសារដាច់ខាតនៃកាតព្វកិច្ចផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ មិនត្រូវបានគេទទួលទទួលយកជាទូទៅនៅក្នុងអក្សរសាស្ត្រច្បាប់នោះទេ។ កត្តាសំខាន់ដែលធ្វើការពន្យល់ការស្ទាក់ស្ទើរនេះ គឺភាពមិនគ្រប់គ្រាន់នៃការអនុវត្តរបស់រដ្ឋដែលបានអះអាងឡើងដើម្បីជាការគាំទ្រដល់បទដ្ឋានដាច់ខាតនេះ (peremptory norm)។

[64] កថាខណ្ឌទី ៣០ នៃសំណើសុំ។

[65] Ilias Bantekas, ការផ្ទុះបញ្ចាំងទៅលើប្រភព និងវិធីសាស្ត្រខ្លះៗនៃច្បាប់ព្រហ្មទណ្ឌ និងច្បាប់មនុស្សធម៌អន្តរជាតិ, 6 INT'L CRIM. LAW REV. 121, 125 (2006)។

[66] រដ្ឋអាជ្ញា តទល់នឹង *Delić,* IT-04-83-PT, សេចក្តីសម្រេចទៅលើសំណើសុំកែប្រែដីកាចោទប្រកាន់ និងសារណារបស់មេធាវីការពារក្តីដែលលើកឡើងពីផលប៉ះពាល់នៅក្នុងដីកាចោទប្រកាន់ដែលបានកែប្រែ ចុះថ្ងៃទី ៣០ មិថុនា ២០០៦ កថាខណ្ឌទី ៥៣ និងកថាខណ្ឌទី ៥៧–៧៤។ បុរេវិនិច្ឆ័យដោយអយុត្តិធម៌នេះអាចបង្ហាញឱ្យឃើញតាមរយៈ (១) ការមិនមានឱកាសគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តីឱ្យមានប្រសិទ្ធភាព ឬ (២)ការពន្យារពេលហួសហេតុចំពោះថេរៈវេលានៃដំណើរការនីតិវិធីមុនសវនាការ កាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការ និងរយៈពេលទូទៅនៃការជំនុំជម្រះក្តី។ សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង *Milan Lukić and Sredoje Lukić,* IT-98-32/1-PT, សេចក្តីសម្រេចទៅលើសំណើសុំរបស់អយ្យការស្វែងរកការអនុញ្ញាតកែប្រែដីកាចោទប្រកាន់ដែលបានកែប្រែលើកទីពីរ និងសំណើរបស់អយ្យការសុំដាក់បញ្ចូលសេចក្តីសម្រេចលេខ ១៨២០ របស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប ជាឯកសារបន្ថែមទៅលើដីកាចោទប្រកាន់ដែលបានស្នើសុំកែប្រែ

00362867



ឃ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនអនុវត្តដោយផ្ទាល់នៅក្នុងតុលាការជាតិទេ

២៩. មិនមានអនុសញ្ញាដែលអះអាងពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល មកលើបុគ្គលទាំងឡាយចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ក្នុងខណៈដែលធម្មនុញ្ញ Nuremberg ចងក្រងជាច្បាប់សរសេរនូវឧក្រិដ្ឋកម្មនេះ[67] មាត្រា ៦(គ) នៃធម្មនុញ្ញនេះចែងច្បាស់ថា ឧក្រិដ្ឋកម្មទាំងនេះទំនងជាមិនមានចែងនៅក្នុងច្បាប់ជាតិរបស់ប្រទេស ដែលឧក្រិដ្ឋកម្មទាំងនេះបានកើតមានឡើង។ ហេតុដូច្នេះ មូលដ្ឋានតែមួយគត់សម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដូចដែលបានពន្យល់លំអិតពីមុនរួចមកហើយ ដោយសារ អវតក ត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់នៃប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសកម្ពុជា នោះតុលាការនេះអាចអនុវត្តបានតែច្បាប់ទំនៀមទម្លាប់អន្តរជាតិប៉ុណ្ណោះ បើសិនជាត្រូវបានអនុញ្ញាត ឬមានកាតព្វកិច្ចដែលមានចែងដោយច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា[68]។ ច្បាប់បង្កើត អវតក នេះ គឺជាច្បាប់តែមួយគត់ ដែលអាចដាក់បញ្ចូល ឬអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយច្បាប់នេះដោយត្រូវបានប្រកាសឱ្យប្រើនៅក្នុងឆ្នាំ ២០០១ អាចគ្រាន់តែដាក់បញ្ចូលតែច្បាប់ទំនៀមទម្លាប់អន្តរជាតិសម្រាប់ឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តក្រោយកាលបរិច្ឆេទនោះតែប៉ុណ្ណោះ។ ចំនុចនេះអាចដកចេញនូវការអនុវត្តន៍ឧក្រិដ្ឋកម្មនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចំពោះអំពើទាំងឡាយដែលបានប្រព្រឹត្តនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

---

លើកទីបី ក៏ដូចជា សំណើររបស់ Milan Lukic សុំឱ្យមានការពិចារណាឡើងវិញ ឬការបញ្ជាក់ពីដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៩ មិថុនា ២០០៨ និង ៨ កក្កដា ២០០៨។

[67] នៅក្នុងការកំណត់ពីយុត្តាធិការរបស់តុលាការ មាត្រា ៥(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ (IMT) ចែងថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មាន "ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល នៅមុន ឬក្នុងអំឡុងពេលនៃសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ឬជាតិសាសន៍ នីក្នុងការអនុវត្តន៍ ឬនៅក្នុងការជាប់ពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្មណាមួយដែលឋិតនៅក្នុងយុត្តាធិការរបស់តុលាការនេះ ទោះបីជាការរំលោភ ឬមិនរំលោភច្បាប់ក្នុងស្រុករបស់ប្រទេសដែលបានប្រព្រឹត្តអំពើនោះក្តី។ មេដឹកនាំ អ្នករៀបចំ អ្នកញុះញង់ និងអ្នកសមគំនិត ដែលចូលរួមក្នុងការតាក់តែង ឬការអនុវត្តន៍ផែនការរួម ឬការសមគំនិតប្រព្រឹត្តឧក្រិដ្ឋកម្មខាងលើ ត្រូវទទួលខុសត្រូវចំពោះអំពើទាំងអស់ដែលបានប្រព្រឹត្តឡើងដោយជនណាម្នាក់នៅក្នុងការផែនការបែបនោះ"។

[68] សូមមើល កថាខណ្ឌទី ៣២-៣៤ នៃចម្លើយតបស្តីពីការបាត់ខ្លួនដោយបង្ខំ។

ង. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលឋិតនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានផ្ទុកនូវធាតុផ្សំអត្តនោម័តនៃការរើសអើង ឬក៏ អវតក អាចដាក់កម្រិតដោយស្របច្បាប់លើយុត្តាធិការរបស់ខ្លួនក្នុងការបញ្ចូលនូវធាតុផ្សំនេះ

៣០. ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនូវជំហរថា “កិច្ចព្រមព្រៀងដែលមិនតម្រូវអោយបង្ហាញចេតនារើសអើង ក្នុងការបញ្ជាក់អោយឃើញនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគួរត្រូវបានគោរពតាម”[69]។ ជាថ្មីម្តងទៀត ប្រភពទាំងអស់បានសំអាងគឺមានក្រោយកាលបរិច្ឆេទ ១៩៧៥-១៩៧៩។ ដោយសន្មតថាមានវិវាទរវាងមាត្រា ៩ នៃកិច្ចព្រមព្រៀង និងមាត្រា ៥ នៃច្បាប់បង្កើតអវតក ទាក់ទងទៅនឹងនិយមន័យនៃការបាត់ខ្លួនដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គ្រាន់តែប៉ះពាល់តែទៅលើយុត្តាធិការរបស់ អវតក ទៅលើឧក្រិដ្ឋកម្មនេះតែប៉ុណ្ណោះ។ ត្រឹមកម្រិតមួយដែលថា អាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងចន្លោះពីឆ្នាំ ១៩៧៥-៧៩ មិនមាននិយមន័យនៃបទល្មើស នៅក្រោយកាលបរិច្ឆេទដែលអំពើល្មើសព្រហ្មទណ្ឌដែលគេចោទប្រកាន់អាចត្រូវបានគេអនុវត្ត ដោយមិនមានការរំលោភគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* (*nullum crimen sine lege*)ឡើយ។ ធម្មតា នៅចន្លោះពីឆ្នាំ ១៩៧៥-១៩៧៩ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់តម្រូវឲ្យមានចេតនារើសអើងទាំងអស់។ ហេតុនេះ ច្បាប់បង្កើត អវតក មិនកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[70]។ ច្បាប់នេះគ្រាន់តែឆ្លុះបញ្ចាំងនិយមន័យនេះតែប៉ុណ្ណោះ។

៣១. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា លក្ខខណ្ឌតម្រូវអំពីចេតនារើសអើងចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាក់កម្រិតយ៉ាងច្បាស់ពីយុត្តាធិការលើបទល្មើស (subject matter) របស់តុលាការនេះ[71]។ ត្រឹមកម្រិតដែលថាថា ការអះអាងនេះត្រឹមត្រូវ វាពិតជាការស្របច្បាប់ទាំងស្រុង និងបង្ហាញពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើត អវតក ។ ច្បាប់បង្កើត អវតក និងកិច្ចព្រមព្រៀង ក៏បានកម្រិតយុត្តាធិការពេលវេលារបស់តុលាការនេះ ចំពោះឧក្រិដ្ឋកម្មដែលចោទថាបានប្រព្រឹត្តនៅចន្លោះពីថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩[72]។ លិខិតុបករណ៍ច្បាប់ទាំង

[69] កថាខណ្ឌទី ២០ នៃសំណើសុំ។

[70] មាត្រា ២ នៃលក្ខន្តិកៈ ICTR តម្រូវឲ្យមានចេតនារើសអើងចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[71] កថាខណ្ឌទី ១៨ នៃសំណើសុំ។

[72] មាត្រា ១ នៃកិច្ចព្រមព្រៀង និងមាត្រា ២ នៃច្បាប់បង្កើត អវតក។

ពីរនេះ ក៏កម្រិតយុត្តាធិការលើបុគ្គលរបស់ អវតក ត្រឹម "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់"[73]។ នេះឆ្លុះបញ្ចាំងពីកម្រិតព្រំដែនយុត្តាធិការលើបុគ្គល និងយុត្តាធិការលើពេលវេលា នៅតុលាការអន្តរជាតិ *ad hoc* និងសាលាជម្រះក្តីដទៃទៀត[74]។

៣២. អវតក "ប្រតិបត្តិការជាស្ថាប័នឯករាជ្យមួយ នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា"[75]។ ហេតុដូច្នេះនៅក្នុងការបង្កើតតុលាការនេះឡើង រាជរដ្ឋាភិបាលកម្ពុជាអាចដាក់កម្រិតដោយស្របច្បាប់ទៅលើយុត្តាធិការរបស់តុលាការនេះ រួមទាំង ការកម្រិតប្រភេទនៃបទល្មើសដែលតុលាការនេះត្រូវធ្វើការផ្តន្ទាទោសផងដែរ។ តាមរយៈមធ្យោបាយនេះ វាមិនមែនជាការរំលោភទៅលើកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងក្នុងការកម្រិតយុត្តាធិការ ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងនោះទេ[76] ប៉ុន្តែ តាមពិតទៅ វាឆ្លុះបញ្ចាំងកាន់តែច្បាស់ថែមទៀតទៅលើកម្មវត្ថុ និងគោលបំណងតាមរយៈការផ្តោតទៅលើការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលនាដែលមានចេតនារើសអើងទៅវិញទេ។

## V. សេចក្តីសន្និដ្ឋាន និង សំណូមពរ

**អាស្រ័យហេតុនេះ** សម្រាប់ហេតុផលដូចដែលបានលើកឡើងនៅក្នុងសេចក្តីឆ្លើយតបនេះ មេធាវីការពារសូមស្នើសុំដោយគោរពដល់សហចៅក្រមស៊ើបអង្កេតសូមអោយ៖

---

[73] ដូចខាងលើ។

[74] មាត្រា ៨ នៃលក្ខន្តិកៈ ICTY កំណត់ពីយុត្តាធិការផ្នែកពេលវេលា និងផ្នែកភូមិសាស្ត្ររបស់ ICTY ចំពោះ "បូរណៈភាពដែនដីនៃអតីតសាធារណៈរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី (the territory of the former Socialist Federal Republic of Yugoslavia) និងអំឡុងពេលចាប់ផ្តើមនៅថ្ងៃទី ១ មករា ១៩៩១"។ មាត្រា ១ នៃលក្ខន្តិកៈ SCSL កំណត់ពីយុត្តាធិការផ្នែកពេលវេលា និងផ្នែកភូមិសាស្ត្ររបស់ ICTY ចំពោះ "បូរណៈភាពដែនដីនៃប្រទេសសៀរ៉ាលេអូន ចាប់តាំងពីថ្ងៃទី ៣០ វិច្ឆិកា ១៩៩៦"។ មាត្រា ១ នៃលក្ខន្តិកៈ ICTR កំណត់ពីយុត្តាធិការផ្នែកភូមិសាស្ត្រ និងផ្នែកបុគ្គលចំពោះ "បូរណៈភាពដែនដីនៃប្រទេសរ៉ាំងដា និងជនជាតិរ៉ាំងដា ដែលទទួលខុសត្រូវចំពោះការរំលោភបំពាន ប្រព្រឹត្តឡើងនៅក្នុងបូរណៈភាពដែនដីនៃរដ្ឋជិតខាង" និងយុត្តាធិការផ្នែកពេលវេលាមកត្រឹម "ចន្លោះថ្ងៃទី ១ មករា ១៩៩៤ និង ៣១ ធ្នូ ១៩៩៤"។

[75] សំណុំរឿងរបស់ **កាំង ហ្គេកអ៊ាវ** ហៅ "ឌុច" លេខ ០០១/១៨-០៧-២០០៧ (អបជ០១), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៣ ធ្នូ ២០០៧ កថាខណ្ឌទី ១៩។

[76] កថាខណ្ឌទី ១៩ នៃសំណើសុំ។

00362870

ឯកសារ: D188/3

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ក. **ច្រានចោល**សំណើសុំបំពេញកិច្ចស៊ើបសួរនេះ។

សូមលោកសហចៅក្រមទទួលយកសេចក្តីឆ្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១១** ខែ**សីហា** ឆ្នាំ **២០០៩**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**